អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងស្បៀងអាហារសម្រាប់ការអប់រំ

# ប័ណ្ណណែនាំអំពីរបៀបដឹកនាំ ការអានដែលដឹកនាំដោយសិស្ស

## ការស្រាវជ្រាវ

ថ្នាក់រៀននៅបឋមសិក្សា ពឹងផ្អែកទាំងស្រុងលើគ្រូបង្រៀន ប៉ុន្តែកុមារក៏អាចជួយគ្នាទៅវិញទៅមកបានដែរ។ ពួកគេអាចអនុវត្តការអានជាក្រុមតូចៗ ប្រសិនបើសៀវភៅនោះពុំសូវពិបាក ឬប្រសិនបើ ពួកគេបានដឹងពីវារួចហើយ។ តួនាទីរបស់គ្រូបង្រៀនគឺត្រូវដើរមើលជុំវិញនិងចាំជួយដល់ក្រុមសិស្សដែលព្យាយាមប្រើវិធីសាស្រ្តអានដែលពួកគាត់ចេះហើយ នៅតែមិនបានជោគជ័យ ។

- ការអានដែលដឹកនាំដោយសិស្សជួយដល់សិស្សឲ្យកាន់តែមានភាពឯករាជ្យក្នុងការអាន
- ពួកគេប្រើប្រាស់វិធីសាស្រ្តខុសៗគ្នា
- ពួកគេជួយគ្នាទៅវិញទៅមក
- ពួកគេមានឱកាសបានអានសៀវភៅច្រើន
- គ្រូបង្រៀនចាំបាច់ត្រូវដឹងអំពីរបៀបចាត់ចែងសិស្សជាក្រុម ដើម្បីធ្វើឲ្យពួកគេអាចធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព
- គ្រូបង្រៀនត្រូវជ្រើសរើសសៀវភៅសម្រាប់ក្រុមនីមួយៗ
- គ្រូបង្រៀនត្រូវមានការរៀបចំឲ្យបានល្អ និងដើរពិនិត្យគ្រប់ក្រុមទាំងអស់

# សេចក្តីណែនាំសម្រាប់ការអានដែលដឹកនាំដោយសិស្ស

រៀបសិស្សជាក្រុមក្នុងមួយក្រុមមានសិស្សពី៦ ទៅ៨នាក់។ ជាទូទៅអ្នកគួរតែរៀបចំឲ្យសិស្សអង្គុយប្រាំមួយក្រុម។

❖ ផ្តល់ឲ្យក្រុមនីមួយៗនូវកញ្ចប់សៀវភៅ BETT ឬសៀវភៅរឿងចម្រុះ។ សៀវភៅទាំងអស់នៅក្នុងកញ្ចប់គួរតែដូចៗគ្នា។ សរុបទៅវានឹងមានកញ្ចប់ប្រាំមួយផ្សេងៗគ្នា ។
❖ គ្រប់ក្រុមទាំងអស់ គួរតែចាប់ផ្តើមដោយការមើលទៅលើក្របសៀវភៅ ហើយនិយាយអំពីអ្វីដែលពួកគេរំពឹងថាសៀវភៅនេះនឹងនិយាយអំពី។
❖ បន្ទាប់មក ពួកគេគួរតែបើកសៀវភៅនេះមើលទាំងអស់ហើយជជែកគ្នាអំពីរូបភាព។
❖ ពួកគេគួរតែពិភាក្សាពីតួអង្គ សាច់រឿង ទីកន្លែង អារម្មណ៍របស់តួអង្គ ដើម្បីដឹងថានៅក្នុងសៀវភៅមានអ្វីខ្លះ ដែលពួកគេបានដឹងឬចេះរួចហើយ។
❖ ប្រើពេលវេលាដែលពួកគេមានចាប់ផ្តើមអានសៀវភៅពីមួយទំព័រទៅមួយទំព័រ។
❖ ពេលពួកគេ ជួបពាក្យដែលមិនអាចអានបាន ពួកគេគួរតែព្យាយាមប្រើវិធីសាស្ត្រផ្សេងៗ។
❖ សិស្សមួយចំនួនអាចចេះអានពាក្យនោះបាន ដូច្នេះគេគួរជួយសមាជិកក្រុមដែលមិនចេះអាន។
❖ ក្នុងក្រុមគួរត្រូវបានលើកទឹកចិត្តឲ្យពិភាក្សាគ្នាអំពីពាក្យពិបាកខ្លះ។
❖ អ្នកអាចផ្តល់ឱ្យក្រុមនីមួយនូវសៀវភៅដូចគ្នាសម្រាប់អាន៥ឬ៦វគ្គ ។
❖ បន្ទាប់មកផ្លាស់ប្តូរសៀវភៅនេះបង្វិលស្របទ្រនិចនាឡិកានៅជុំវិញថ្នាក់រៀន រហូតដល់សិស្សទាំងអស់បានអានសៀវភៅទាំងប្រាំមួយមុខទាំងអស់គ្នាគ្រប់ក្រុម។

*១០នាទីគឺគ្រប់គ្រាន់សម្រាប់សិស្សដឹកនាំការអាននេះ។*

ខាងក្រោមនេះគឺជាតំណភ្ជាប់ទៅកាន់វីដេអូ ដែលអ្នកអាចមើលពីរបៀបដែលគ្រូបានរៀបចំការអានដឹកនាំសិស្ស។



Comprehension Activity

អំណានដែលដឹកនាំដោយសិស្ស ថ្នាក់ទី១, ទី២ និង ទី៣

សូមចូល មើល(វីដេអូ) តាមវើបសាយខាងក្រោម :

https://drive.google.com/open?id=13b6JoMdPvQkmMafrllOemVohMzCrJ7h0
https://youtu.be/1HzUgTtSLX8
https://youtu.be/ExzQXBJBisY
https://youtu.be/pf_nSUDrybM